**មាត្រា១:** ត្រូវបានបំពាក់ **មេដាយស្ថាបនាជាតិ** តាមលំដាប់ថ្នាក់ ប្រគេននិងជូនសប្បុរសជន ចំនួន២៥រូប ដែលបានបរិច្ចាគធនធានផ្ទាល់ខ្លួន ជួយកសាងសមិទ្ធផលនានា១ក្នុងវិស័យព្រះពុទ្ធសាសនា អប់រំ សង្គមកិច្ច និងហេដ្ឋារចនាសម្ព័ន្ធគមនាគមន៍ នៅវត្តឯក ហៅ (វត្តត្នោត) ស្ថិតក្នុងឃុំត្នោត និងឃុំសំឡី ស្រុកកំពង់រោទិ៍ ខេត្តស្វាយរៀង ដូចមានរាយព្រះនាមនិងនាមខាងក្រោម :-

**ក-មេដាយមាសស្ថាបនាជាតិ :**

| | | | |
|---|---|---|---|
| ១-ព្រះតេជគុណ | ក្មួញ ខាន់រតនា | គង់នៅវត្តចាន់ រាជធានីភ្នំពេញ | បច្ច័យចំនួន ១០.៦០៣ ដុល្លារ |
| ២-ព្រះតេជគុណ | រាជ អ៊ីក | ព្រះចៅអធិការវត្តឯក | បច្ច័យចំនួន ១០.១៧០ ដុល្លារ |
| ៣-អ្នកស្រី | ទុំ សាលឿន | សប្បុរសជននៅខេត្តស្វាយរៀង | ថវិកាចំនួន ១១.០៣០ ដុល្លារ |
| ៤-អ្នកស្រី | រាជ សារុន | សប្បុរសជននៅរាជធានីភ្នំពេញ | ថវិកាចំនួន ១០.៧៥៥ ដុល្លារ |
| ៥-លោក | ពៅ ផល | សប្បុរសជននៅខេត្តស្វាយរៀង | ថវិកាចំនួន ១០.៥៥០ ដុល្លារ |
| ៦-អ្នកស្រី | សុខ ណាត | សប្បុរសជននៅខេត្តស្វាយរៀង | ថវិកាចំនួន ១០.១៣៥ ដុល្លារ |
| ៧-លោក | អ៊ិន តិន | សប្បុរសជននៅរាជធានីភ្នំពេញ | ថវិកាចំនួន ១០.០៦៥ ដុល្លារ |
| ៨-លោក | ឡុង តារ៉ា | សប្បុរសជននៅរាជធានីភ្នំពេញ | ថវិកាចំនួន ១០.០៣០ ដុល្លារ |
| ៩-លោក | សាន់ អុន | អាចារ្យវត្តឯក | ថវិកាចំនួន ១០.០២០ ដុល្លារ |
| ១០-លោក | ព្រហ្ម ឌីក | សប្បុរសជននៅរាជធានីភ្នំពេញ | ថវិកាចំនួន ១០.០១៥ ដុល្លារ |

**ខ-មេដាយប្រាក់ស្ថាបនាជាតិ :**

| | | | | |
|---|---|---|---|---|
| ១-ព្រះតេជគុណ | ញៀម ស៊ីណា | គង់នៅវត្តថាន់ រាជធានីភ្នំពេញ | បច្ច័យចំនួន | ៥.០០៨ ដុល្លារ |
| ២-លោក | ពេជ ជុន | មេឃុំត្នោត | ថវិកាចំនួន | ៥.២៣០ ដុល្លារ |
| ៣-អ្នកស្រី | ពិន សារុន | សប្បុរសជននៅរាជធានីភ្នំពេញ | ថវិកាចំនួន | ៥.១៣០ ដុល្លារ |
| ៤-លោក | អ៊ុំ ទន្លី | សប្បុរសជននៅរាជធានីភ្នំពេញ | ថវិកាចំនួន | ៥.១០៣ ដុល្លារ |
| ៥-អ្នកស្រី | ត្នូច សារី | សប្បុរសជននៅខេត្តស្វាយរៀង | ថវិកាចំនួន | ៥.០៨២ ដុល្លារ |
| ៦-លោក | សំ ថា | សប្បុរសជននៅខេត្តស្វាយរៀង | ថវិកាចំនួន | ៥.០៧០ ដុល្លារ |
| ៧-លោក | សាន់ សំអាត | សប្បុរសជននៅខេត្តស្វាយរៀង | ថវិកាចំនួន | ៥.០៦៥ ដុល្លារ |

**គ-មេដាយសំរិទ្ធស្ថាបនាជាតិ :**

| | | | | |
|---|---|---|---|---|
| ១-លោក | ស្រី វ៉ាច់ | អាចារ្យវត្តឯក | ថវិកាចំនួន | ១.៣៧២ ដុល្លារ |
| ២-លោក | នួន ម៉ុននឿន | សប្បុរសជននៅខេត្តស្វាយរៀង | ថវិកាចំនួន | ១.១៣០ ដុល្លារ |
| ៣-លោក | សន សាមិត | សប្បុរសជននៅខេត្តស្វាយរៀង | ថវិកាចំនួន | ១.១០៣ ដុល្លារ |
| ៤-លោក | ភ្ញា ផន | សប្បុរសជននៅខេត្តស្វាយរៀង | ថវិកាចំនួន | ១.០៦៥ ដុល្លារ |
| ៥-លោក | សុច សាមឿន | សប្បុរសជននៅរាជធានីភ្នំពេញ | ថវិកាចំនួន | ១.០៥០ ដុល្លារ |
| ៦-អ្នកស្រី | ចាប មុំ | សប្បុរសជននៅខេត្តស្វាយរៀង | ថវិកាចំនួន | ១.០៣០ ដុល្លារ |
| ៧-លោក | យួរ យ៉ែន | គណៈកម្មការវត្តឯក | ថវិកាចំនួន | ១.០៣០ ដុល្លារ |
| ៨-លោក | ម៉ៅ សារឿន | សប្បុរសជននៅរាជធានីភ្នំពេញ | ថវិកាចំនួន | ១.០២០ ដុល្លារ |

**មាត្រា២ :** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និង អភិបាលខេត្តស្វាយរៀង ត្រូវអនុវត្តអនុក្រឹត្យនេះ អោយទទួលបានលទ្ធផលល្អ ។

រាជធានីភ្នំពេញ ថ្ងៃទី [illegible] ឆ្នាំ ២០០៩

**កន្លែងទទួល:**
- -ក្រសួងព្រះបរមរាជវាំង
- -អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- -អគ្គលេខាធិការដ្ឋានរដ្ឋសភា
- -អគ្គលេខាធិការរាជរដ្ឋាភិបាល
- -ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- -ដូចមាត្រា ១ និង មាត្រា ២
- -រាជកិច្ច
- -ឯកសារ-កាលប្បវត្តិ

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

# ព្រះរាជាណាចក្រកម្ពុជា

## ជាតិ សាសនា ព្រះមហាក្សត្រ

**រាជរដ្ឋាភិបាលកម្ពុជា**

**លេខ:** ៧៣៥ អនក្រ.បក

## អនុក្រឹត្យ

## ស្តីពីការជូនមេដាយស្ថាបនាជាតិ

## រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រឹត្យ លេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើតនិងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា

-តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

## សម្រេច

**មាត្រា១:** ត្រូវបានបំពាក់ **មេដាយស្ថាបនាជាតិ** តាមលំដាប់ថ្នាក់ ប្រគេននិងជូនសប្បុរសជន ចំនួន១៣រូប ដែលបានបរិច្ចាគធនធានផ្ទាល់ខ្លួន ជួយកសាងព្រះវិហារ វិច្ចកុដិ របងវត្ត ខ្លោងទ្វារ ម៉ាស៊ីនភ្លើង និងសមិទ្ធផលផ្សេងៗទៀតនៅវត្តធម្មរង្សី ហៅ វត្តតាប្រុក ស្ថិតនៅក្នុងឃុំឈូកខ្សាច់ ស្រុកបារាយណ៍ ខេត្តកំពង់ធំ ដូចមានរាយព្រះនាមនិងនាមខាងក្រោម :-

**ក-មេដាយមាសស្ថាបនាជាតិ :**

| | | | |
|---|---|---|---|
| ១-ព្រះតេជគុណ | ពៅ ស្មៀន | ព្រះចៅអធិការវត្តធម្មរង្សី | បច្ច័យចំនួន ២៨.២៧៣ ដុល្លារ |
| ២-ឧបាសក | ខាត់ ខែត | អាចារ្យវត្តធម្មរង្សី | ថវិកាចំនួន ១៦.១៣៥ ដុល្លារ |
| ៣-លោក | កែ សុត | គណៈកម្មការវត្តធម្មរង្សី | ថវិកាចំនួន ១១.៣៧៩ ដុល្លារ |

**ខ-មេដាយប្រាក់ស្ថាបនាជាតិ :**

| | | | |
|---|---|---|---|
| ១-ព្រះតេជគុណ | អ៊ឹម មុនី | គង់នៅវត្តធម្មរង្សី | បច្ច័យចំនួន ៩.៤៨១ ដុល្លារ |
| ២-ព្រះតេជគុណ | ប៊ុច ណាឃីន | គង់នៅវត្តធម្មរង្សី | បច្ច័យចំនួន ៩.០៥៧ ដុល្លារ |
| ៣-ព្រះតេជគុណ | សំម សុវណ្ណ | គង់នៅវត្តធម្មរង្សី | បច្ច័យចំនួន ៨.៩៦៣ ដុល្លារ |
| ៤-ព្រះតេជគុណ | អ៊ំ សុឈុន | គង់នៅវត្តធម្មរង្សី | បច្ច័យចំនួន ៨.៥៤៤ ដុល្លារ |
| ៥-លោក | ហឿន យុទ្ធធីរ | ប្រធានការិយាល័យធម្មការខេត្ត | ថវិកាចំនួន ៧.៧៣៤ ដុល្លារ |
| ៦-លោក | សោម ស្មៀន | គណៈកម្មការវត្តធម្មរង្សី | ថវិកាចំនួន ៦.៤៩៣ ដុល្លារ |
| ៧-លោក | ចៅ អុល | អាចារ្យរងវត្តធម្មរង្សី | ថវិកាចំនួន ៥.២០៣ ដុល្លារ |

**គ-មេដាយសំរឹទ្ធស្ថាបនាជាតិ :**

| | | | |
|---|---|---|---|
| ១-ឧបាសិកា | ឃិន យ៉ាន់ | សប្បុរសជននៅរាជធានីភ្នំពេញ | ថវិកាចំនួន ៤.៥១៣ ដុល្លារ |
| ២-លោក | ថ្មី ថេន | អាចារ្យរងវត្តធម្មរង្សី | ថវិកាចំនួន ៤.២៧៧ ដុល្លារ |
| ៣-លោក | សួរ សឿង | សប្បុរសជននៅខេត្តកំពង់ធំ | ថវិកាចំនួន ២.១១៦ ដុល្លារ |

**មាត្រា២:** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និង អភិបាលខេត្តកំពង់ធំ ត្រូវអនុវត្តអនុក្រឹត្យនេះ អោយទទួលបានលទ្ធផលល្អ ។

រាជធានីភ្នំពេញ ថ្ងៃទី [illegible] ខែ [illegible] ឆ្នាំ២០០៩

នាយករដ្ឋមន្ត្រី

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**កន្លែងទទួល:**

-ក្រសួងព្រះបរមរាជវាំង
-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
-អគ្គលេខាធិការដ្ឋានរដ្ឋសភា
-អគ្គលេខាធិការរាជរដ្ឋាភិបាល
-ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
-ដូចមាត្រា ១ និង មាត្រា ២
-រាជកិច្ច
-ឯកសារ-កាលប្បវត្តិ

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

**លេខ:** ១១៤០ . អនក្រ.បក

# អនុក្រឹត្យ

## ស្តីពីការជូនមេដាយស្ថាបនាជាតិ

## រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រឹត្យ លេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើតនិងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា

-តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងធម្មការ និងសាសនា

## សម្រេច

**មាត្រា១:** ត្រូវបានបំពាក់ **មេដាយស្ថាបនាជាតិ** តាមលំដាប់ថ្នាក់ ប្រគេននិងជូនសប្បុរសជន ចំនួន ០៦រូប ដែលបានបរិច្ចាគធនធាន ចូលរួមជួយកសាងសាលាធម្មសភា និងផ្លូវបេតុង នៅវត្តក្តីរុនរស្សី ឃុំក្តីរុន ស្រុកពួក ខេត្តសៀមរាប ដូចមានរាយព្រះនាមនិងនាមខាងក្រោម :-

**ក-មេដាយមាសស្ថាបនាជាតិ :**

-ព្រះតេជគុណ **ឡាំ ឃ្លី** បានចំណាយបច្ច័យ ចំនួន ២០.០០០ ដុល្លារ

**ខ-មេដាយប្រាក់ស្ថាបនាជាតិ :**

១-ឧបាសក **អ៊ុច ហួរ** បានចំណាយថវិកា ចំនួន ៦.០០០ ដុល្លារ

២-ឧបាសិកា **ជន ម៉ន** បានចំណាយថវិកា ចំនួន ៥.០០០ ដុល្លារ

៣-ឧបាសក **ទិវ ប៊ុនស៊ាន** បានចំណាយថវិកា ចំនួន ៥.០០០ ដុល្លារ

៤-ឧបាសក **អៀ ប្រុច** បានចំណាយថវិកា ចំនួន ៥.០០០ ដុល្លារ

**គ-មេដាយសំរឹទ្ធស្ថាបនាជាតិ :**

-ឧបាសិកា **សុខ ភន** បានចំណាយថវិកា ចំនួន ៣.០០០ ដុល្លារ

**មាត្រា២:** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងធម្មការ និងសាសនា និងអភិបាលខេត្តសៀមរាប ត្រូវអនុវត្តអនុក្រឹត្យនេះ អោយទទួលបានលទ្ធផលល្អ ។

ធ្វើនៅភ្នំពេញ ថ្ងៃទី [illegible] ខែ មិថុនា ឆ្នាំ ២០០៩

នាយករដ្ឋមន្ត្រី

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**កន្លែងទទួល:**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចមាត្រា ១ និង មាត្រា ២
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

**លេខៈ** ១១៤១ . អនក្រ.បក

# អនុក្រឹត្យ

## ស្តីពីការជូនមេដាយស្ថាបនាជាតិ

**រាជរដ្ឋាភិបាល**

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រឹត្យ លេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើតនិងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា

-តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងធម្មការ និងសាសនា

**សម្រេច**

**មាត្រា១:** ត្រូវបានបំពាក់ **មេដាយមាសស្ថាបនាជាតិ** ជូនសប្បុរសជន ចំនួន០៥រូប ដែលបានបរិច្ចាគធនធានផ្ទាល់ខ្លួនចូលរួមកសាងព្រះវិហារ ដងទង់ និង សមិទ្ធផលមួយចំនួនទៀត នៅវត្តនទីរិន្ត ឃុំតាំងស្យា ស្រុកភ្នំស្រួច ខេត្តកំពង់ស្ពឺ ដូចមានរាយនាមខាងក្រោម :-

| | | | |
|---|---|---|---|
| ១-លោក | **ហួរ** | **សុខហេង** | ថវិកា ចំនួន ១២.២៥០ ដុល្លារ |
| ២-អ្នកស្រី | **សូ** | **សុរិយា** | ថវិកា ចំនួន ១១.៤០០ ដុល្លារ |
| ៣-លោកជំទាវ | **សូ** | **ភក្ត្រា** ភរិយា ឯកឧត្តម **ចាយ បូរិន** | ថវិកា ចំនួន ១១.២៥០ ដុល្លារ |
| ៤-អ្នកស្រី | **គោ** | **ទូចហ៊ីង** | ថវិកា ចំនួន ១១.៧០០ ដុល្លារ |
| ៥-អ្នកស្រី | **គោ** | **ណារឿន** | ថវិកា ចំនួន ១១.៧៥០ ដុល្លារ |

**មាត្រា២:** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងធម្មការនិងសាសនា និងអភិបាលខេត្តកំពង់ស្ពឺ ត្រូវអនុវត្តអនុក្រឹត្យនេះ អោយទទួលបានលទ្ធផលល្អ

រាជធានីភ្នំពេញ ថ្ងៃទី ១៦ ខែ មិថុនា ឆ្នាំ២០០៩

នាយករដ្ឋមន្ត្រី

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**កន្លែងទទួល :**

-ក្រសួងព្រះបរមរាជវាំង
-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
-អគ្គលេខាធិការដ្ឋានរដ្ឋសភា
-អគ្គលេខាធិការរាជរដ្ឋាភិបាល
-ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
-ដូចមាត្រា ១ និង មាត្រា ២
-រាជកិច្ច
-ឯកសារ-កាលប្បវត្តិ

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**
**លេខ:** ១១៤៧ អនក្រ.បក

# អនុក្រឹត្យ
## ស្តីពីការជូនមេដាយមុនីសារាភ័ណ្ឌ

## រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
-បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
-បានឃើញព្រះរាជក្រឹត្យ លេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើតនិងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា
-តាមសំណើរបស់មេបញ្ជាការកងទ័ពជើងគោក

## សម្រេច

**មាត្រា១:** ត្រូវបានបំពាក់ **មេដាយមុនីសារាភ័ណ្ឌ** ថ្នាក់ **ធិបឌិន្ទ** ជូនសប្បុរសជន ចំនួន០៥រូប ដែលបានបរិច្ចាគធនធានផ្ទាល់ខ្លួនចូលរួមជួយកសាងអគាររដ្ឋបាល ដល់ទីបញ្ជាការដ្ឋានយោធភូមិភាគពិសេស និងរួមចំណែកជួយឧបត្ថម្ភដល់គ្រួសារយោធិន ជួបការលំបាកជាច្រើនគ្រួសារ ដូចមានរាយនាមខាងក្រោម :-

១-ឯកឧត្តម **ហុង ពីថ** ទីប្រឹក្សាសម្តេចអគ្គមហាធម្មពោធិសាល **ជា ស៊ីម**
២-លោក **ហាក់ សែ** ហាងលក់ទូរស័ព្ទដៃ
៣-លោក **អ៊ឹង ម៉េងជី** ហាងលក់គ្រឿងអលង្ការ
៤-លោក **ហោ ម៉េង** អគ្គនាយកក្រុមហ៊ុន សូនីស៊ីនម៉ិចកូ
៥-លោក **សេង ម៉េង** នាយកក្រុមហ៊ុន HMH

**មាត្រា២:** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងការពារជាតិ និង មេបញ្ជាការកងទ័ពជើងគោក ត្រូវអនុវត្តអនុក្រឹត្យនេះ អោយទទួលបានលទ្ធផលល្អ ។

រាជធានីភ្នំពេញ ថ្ងៃទី [illegible] ខែ [illegible] ឆ្នាំ ២០០៩
**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**កន្លែងទទួល:**
-ក្រសួងព្រះបរមរាជវាំង
-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
-អគ្គលេខាធិការដ្ឋានរដ្ឋសភា
-អគ្គលេខាធិការរាជរដ្ឋាភិបាល
-ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
-ដូចមាត្រា ១ និង មាត្រា ២
-រាជកិច្ច
-ឯកសារ-កាលប្បវត្តិ

# ព្រះរាជាណាចក្រកម្ពុជា
## ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខៈ ១១៤៣ អនក្រ.តត

## អនុក្រឹត្យ
## ស្តីពីការតែងតាំងមន្ត្រីរាជការ

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យ លេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រម លេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃ គណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រម លេខ នស/រកម/០១៩៦/០៩ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតទីស្តីការគណៈរដ្ឋមន្ត្រី
- យោងតាមតម្រូវការការងារចាំបាច់របស់រាជរដ្ឋាភិបាល

## សម្រេច

**មាត្រា ១ :** តែងតាំងលោក ហូ សិទ្ធីគុណ ជាជំនួយការឯកឧត្តម ស៊ើ ចាំមរុង្គ រដ្ឋមន្ត្រីប្រតិភូអមនាយករដ្ឋមន្ត្រី មានឋានៈស្មើ ប្រធាននាយកដ្ឋាន បន្ថែមលើមុខងារបច្ចុប្បន្ន ។

**មាត្រា ២ :** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងការពារជាតិ រដ្ឋលេខាធិការនៃ រដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ រដ្ឋមន្ត្រី រដ្ឋលេខាធិការគ្រប់ក្រសួង ស្ថាប័នដែលពាក់ព័ន្ធ និងសាមីខ្លួន ដូចមានចែងក្នុងមាត្រា ១ ត្រូវអនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃ ចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី [illegible] ឆ្នាំ២០០៩

**កន្លែងទទួល :**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា ២
- ឯកសារ-កាលប្បវត្តិ

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខៈ ១១៤៤ ..អនក្រ.តត

# អនុក្រឹត្យ
## ស្តីពីការតែងតាំងមន្ត្រីរាជការ

### រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យ លេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រម លេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃ គណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រម លេខ នស/រកម/០១៩៦/០៩ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតទីស្តីការគណៈរដ្ឋមន្ត្រី
- យោងតាមតម្រូវការការងារចាំបាច់របស់រាជរដ្ឋាភិបាល

### សម្រេច

**មាត្រា ១ :** តែងតាំងលោក គីម សុវណ្ណា ជាជំនួយការឯកឧត្តម ហូ សិទ្ធី រដ្ឋមន្ត្រីប្រតិភូអមនាយករដ្ឋមន្ត្រី មានឋានៈស្មើ ប្រធាននាយកដ្ឋាន បន្ថែមលើមុខងារបច្ចុប្បន្ន ។

**មាត្រា ២ :** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋលេខាធិការនៃរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ រដ្ឋមន្ត្រី រដ្ឋលេខាធិការគ្រប់ក្រសួង ស្ថាប័នដែលពាក់ព័ន្ធ និងសាម៉ីខ្លួន ដូចមានចែងក្នុងមាត្រា ១ ត្រូវអនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃ ចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី ១៤ ខែ មិថុនា ឆ្នាំ ២០០៩

នាយករដ្ឋមន្ត្រី

សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន

**កន្លែងទទួល :**
- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា ២
- ឯកសារ-កាលប្បវត្តិ

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

**លេខ: ១១៤៥ .អនក្រ.បក**

# អនុក្រឹត្យ

## ស្តីពីការជូនមេដាយមុនីសារាភ័ណ្ឌ

**រាជរដ្ឋាភិបាល**

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រឹត្យ លេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើតនិងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា

-តាមសំណើរបស់ អភិបាលខេត្តព្រៃវែង

**សម្រេច**

**មាត្រា១:** ត្រូវបានបំពាក់ **មេដាយមុនីសារាភ័ណ្ឌ** តាមលំដាប់ថ្នាក់ ជូនសប្បុរសជន ចំនួន០៤រូប ដែលបានបរិច្ចាគធនធានផ្ទាល់ខ្លួន ចូលរួមចំណែកជួយកសាងនិងជួសជុលព្រះវិហារ កសាងមហាកុដិ តួរតំនួរ របងវត្ត ឧបដ្ឋានសាលា ចាក់ដីបំពេញទីធ្លាវត្ត និងសមិទ្ធផលនានានៅក្នុងវត្តសុវណ្ណរង្សី ស្ថិតនៅភូមិលេខ២ សង្កាត់កំពង់លាវ ក្រុងព្រៃវែង ខេត្តព្រៃវែង ដូចមានរាយនាមខាងក្រោម :-

**ក-មេដាយមុនីសារាភ័ណ្ឌ ថ្នាក់ សេនា :**

| | | | |
|---|---|---|---|
| ១-លោកជំទាវ **ស៊ាន ឈុនហេង** | សប្បុរសជននៅខេត្តព្រះសីហនុ | ថវិកាចំនួន ៣០.២០០ ដុល្លារ |
| ២-ឧបាសិកា **លន់ គត់** | សប្បុរសជននៅស្វាយអន្ទរ | ថវិកាចំនួន ៣០.១០០ ដុល្លារ |
| ៣-ឯកឧត្តម **លី ឆេង** | អគ្គនាយកប៉ៃលិនគ្រុប | ថវិកាចំនួន ៣០.១០០ ដុល្លារ |

**ខ-មេដាយមុនីសារាភ័ណ្ឌ ថ្នាក់ អស្សឫទ្ធិ :**

| | | |
|---|---|---|
| -លោកជំទាវ **ម៉ក់ ជឹម** | សប្បុរសជននៅខេត្តព្រៃវែង | ថវិកាចំនួន ២៤.១០០ ដុល្លារ |

**មាត្រា២:** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និង អភិបាលខេត្តព្រៃវែង ត្រូវអនុវត្តអនុក្រឹត្យនេះ អោយទទួលបានលទ្ធផលល្អ ។

រាជធានីភ្នំពេញ ថ្ងៃទី ២៦ ខែ មិថុនា ឆ្នាំ ២០០៩

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**កន្លែងទទួល:**

-ក្រសួងព្រះបរមរាជវាំង
-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
-អគ្គលេខាធិការដ្ឋានរដ្ឋសភា
-អគ្គលេខាធិការរាជរដ្ឋាភិបាល
-ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
-ដូចមាត្រា ១ និង មាត្រា ២
-រាជកិច្ច
-ឯកសារ-កាលប្បវត្តិ

# ព្រះរាជាណាចក្រកម្ពុជា
## ជាតិ សាសនា ព្រះមហាក្សត្រ

**រាជរដ្ឋាភិបាលកម្ពុជា**

**លេខ:**១១៤៦ . អនក្រ.បក

## អនុក្រឹត្យ
## ស្តីពីការជូនមេដាយស្ថាបនាជាតិ

## រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រឹត្យ លេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើតនិងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា

-តាមសំណើរបស់អភិបាលខេត្តព្រៃវែង

## សម្រេច

**មាត្រា១:** ត្រូវបានបំពាក់ **មេដាយស្ថាបនាជាតិ** តាមលំដាប់ថ្នាក់ ជូនសប្បុរសជន ចំនួន១១រូប ដែលបានបរិច្ចាគធនធានផ្ទាល់ខ្លួន ចូលរួមចំណែកជួយកសាងនិងជួសជុលព្រះវិហារ កសាងមហាកុដិ គួរគំនូរ របងវត្ត ឧបដ្ឋានសាលាចាក់ដីបំពេញទីធ្លាវត្ត និងសមិទ្ធផលនានានៅក្នុងវត្តសុវណ្ណរង្សី ស្ថិតនៅភូមិលេខ២ សង្កាត់កំពង់លាវ ក្រុងព្រៃវែង ខេត្តព្រៃវែង ដូចមានរាយនាមខាងក្រោម :-

**ក-មេដាយមាសស្ថាបនាជាតិ :**

| | | |
|---|---|---|
| ១-ឯកឧត្តម **សុខ ផេង** | ទីប្រឹក្សាសម្តេច ជា ស៊ីម | ថវិកាចំនួន ១១.១៥០ ដុល្លារ |
| ២-លោកស្រី **ទេព្វ សំអូន** | អភិបាលរងខេត្តព្រៃវែង | ថវិកាចំនួន ១១.១១០ ដុល្លារ |
| ៣-លោក **ស៊ុយ អាង** | សប្បុរសជននៅភ្នំពេញ | ថវិកាចំនួន ១១.000 ដុល្លារ |
| ៤-លោក **លី ម៉េងលាង** | សប្បុរសជននៅភ្នំពេញ | ថវិកាចំនួន ១០.000 ដុល្លារ |
| ៥-លោក **អន អុន** | សប្បុរសជននៅភ្នំពេញ | ថវិកាចំនួន ១០.000 ដុល្លារ |
| ៦-លោក **លី ឈាង** | សប្បុរសជននៅភ្នំពេញ | ថវិកាចំនួន ១០.000 ដុល្លារ |
| ៧-លោក **គីម សាន់** | សប្បុរសជននៅស្រុកកញ្ជ្រៀច | ថវិកាចំនួន ១០.000 ដុល្លារ |
| ៨-ឧបាសិកា **ជា អេង** | សប្បុរសជននៅខេត្តព្រៃវែង | ថវិកាចំនួន ១០.00៨ ដុល្លារ |

ខ.មេដាយប្រាក់ស្ថាបនាជាតិ :

-ព្រះតេជគុណ គីម សុគន្ធ សមណៈនិស្សិត នៅភ្នំពេញ ថវិកាចំនួន ៥.២០០ ដុល្លារ

គ.មេដាយសំរឹទ្ធស្ថាបនាជាតិ :

១-លោក នុត នួន សប្បុរសជននៅភ្នំពេញ ថវិកាចំនួន ២.៥០០ ដុល្លារ

២-លោក យក់ ឡាំ សប្បុរសជននៅខេត្តព្រៃវែង ថវិកាចំនួន ២.២០០ ដុល្លារ

**មាត្រា២ៈ** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និង អភិបាលខេត្តព្រៃវែង ត្រូវអនុវត្ត អនុក្រឹត្យនេះ អោយទទួលបានលទ្ធផលល្អ ។

រាជធានីភ្នំពេញ ថ្ងៃទី ២៣ ខែ មិថុនា ឆ្នាំ២០០៩

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**កន្លែងទទួល:**

-ក្រសួងព្រះបរមរាជវាំង
-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
-អគ្គលេខាធិការដ្ឋានរដ្ឋសភា
-អគ្គលេខាធិការរាជរដ្ឋាភិបាល
-ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
-ដូចមាត្រា ១ និង មាត្រា ២
-រាជកិច្ច
-ឯកសារ-កាលប្បវត្តិ

# ព្រះរាជាណាចក្រកម្ពុជា

## ជាតិ សាសនា ព្រះមហាក្សត្រ

**រាជរដ្ឋាភិបាលកម្ពុជា**

លេខៈ ១៤៧ អនក្រ.បក

# អនុក្រឹត្យ

## ស្តីពីការជូនមេដាយស្ថាបនាជាតិ

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យ លេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើតនិងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា
- តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

## សម្រេច

**មាត្រា១:** ត្រូវបានបំពាក់ **មេដាយមាសស្ថាបនាជាតិ** ប្រគេននិងជូនសប្បុរសជន ចំនួន០៣រូប ដែលបាន បរិច្ចាគធនធានជួយកសាងព្រះវិហារថ្មី សាលាធម្មសភា ខ្លោងទ្វារ និងអាស្រមឥសី នៅវត្តពោធិវង្សីរតនារាម ហៅ វត្តពីត ឃុំស្ទឹង ស្រុកបាណន់ ខេត្តបាត់ដំបង ដូចមានរាយព្រះនាម និងនាមខាងក្រោម :-

១-ព្រះតេជគុណ **ខង្ស ស៊ីដេត** ព្រះចៅអធិការវត្តពោធិវង្សីរតនារាម បានបរិច្ចាគបច្ច័យចំនួន ១០.០០០ ដុល្លារ

២-លោក **ឆាន់ ច័ាន់ហិញ** និងអ្នកស្រី **យ៉ាំ ឆួយ** នៅសហរដ្ឋអាមេរិក ថវិកាចំនួន ១៦៦.៩០០ ដុល្លារ

៣-លោក **តូ ជួយ** និងអ្នកស្រី **ទីច ហាំខ** នៅខេត្តបាត់ដំបង ថវិកាចំនួន ១០.០០០ ដុល្លារ

**មាត្រា២:** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និងអភិបាលខេត្តបាត់ដំបង ត្រូវអនុវត្តអនុក្រឹត្យនេះអោយទទួលបានលទ្ធផលល្អ ។

រាជធានីភ្នំពេញ ថ្ងៃទី ១៧ ខែ មិថុនា ឆ្នាំ២០០៩

នាយករដ្ឋមន្ត្រី

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**កន្លែងទទួល :**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចមាត្រា ១ និង មាត្រា ២
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

**លេខៈ** ១១៤៩ អនក្រ.បក

# អនុក្រឹត្យ

## ស្តីពីការជូនមេដាយមុនីសារាភ័ណ្ឌ

## រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រឹត្យ លេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើតនិងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា

-តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

## សម្រេច

**មាត្រា១:** ត្រូវបានបំពាក់ **មេដាយមុនីសារាភ័ណ្ឌ** ថ្នាក់ **ធិបឌិន្ទ** ជូនលោក **ហោ គីមសៀង** សប្បុរសជននៅខេត្តបាត់ដំបង ដែលបានចំណាយថវិកាចំនួន ៧៧.៣៦៥ ដុល្លារ ចូលរួមកសាងព្រះវិហារ សាលាធម្មសភា កុដិ សាលារៀន ខ្លោងទ្វារវត្ត និងសមិទ្ធផលផ្សេងៗជាច្រើនទៀត នៅវត្តសុវណ្ណារាម ហៅ វត្តអូរក្របៅ ឃុំមោងស្រុកមោងឫស្សី និងព្រះវិហារ នៅវត្តពីត ស្ថិតនៅឃុំស្ទឹង ស្រុកបាណន់ ខេត្តបាត់ដំបង ។

**មាត្រា២:** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និង អភិបាលខេត្តបាត់ដំបង ត្រូវអនុវត្តអនុក្រឹត្យនេះ អោយទទួលបានលទ្ធផលល្អ ។

រាជធានីភ្នំពេញ ថ្ងៃទី [illegible] ខែ មិថុនា ឆ្នាំ ២០០៩

នាយករដ្ឋមន្ត្រី

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**កន្លែងទទួល:**

-ក្រសួងព្រះបរមរាជវាំង

-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា

-អគ្គលេខាធិការដ្ឋានរដ្ឋសភា

-អគ្គលេខាធិការរាជរដ្ឋាភិបាល

-ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី

-ដូចមាត្រា ១ និង មាត្រា ២

-រាជកិច្ច

-ឯកសារ-កាលប្បវត្តិ

# ព្រះរាជាណាចក្រកម្ពុជា

## ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខៈ ១១៤៥ អនក្រ.បក

# អនុក្រឹត្យ

## ស្តីពីការជូនមេដាយស្ថាបនាជាតិ

## រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រឹត្យ លេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើតនិងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា

-តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

## សម្រេច

**មាត្រា១ៈ** ត្រូវបានបំពាក់ **មេដាយស្ថាបនាជាតិ** តាមលំដាប់ថ្នាក់ ប្រគេននិងជូនសប្បុរសជន ចំនួន១៥រូប ដែលបានបរិច្ចាគបច្ច័យនិងថវិកា ចូលរួមកសាងព្រះវិហារ សាលាធម្មសភា កុដិ សាលារៀន ខ្លោងទ្វារវត្ត និងសមិទ្ធផលផ្សេងៗជាច្រើនទៀត នៅវត្តសុវណ្ណារាម ហៅ វត្តអូរក្រចៅ ឃុំមោង ស្រុកមោងឫស្សី និងព្រះវិហារនៅវត្តពីតស្ថិតនៅឃុំស្ទឹង ស្រុកបាណន់ ខេត្តបាត់ដំបង ដូចមានរាយព្រះនាមនិងនាមខាងក្រោម :-

**ក.មេដាយមាសស្ថាបនាជាតិ :**

| | | |
|---|---|---|
| ១-ព្រះតេជគុណ **សំ ភន** | ព្រះចៅអធិការវត្តសុវណ្ណារាម | បច្ច័យចំនួន ១៤.២១០ ដុល្លារ |
| ២-អ្នកស្រី **យ៉ាំ ឆួយ** | សប្បុរសជននៅសហរដ្ឋអាមេរិក | ថវិកាចំនួន ៣៥.៣២០ ដុល្លារ |
| ៣-លោក **ទេព ហាន** | អភិបាលរងស្រុកមោងឫស្សី | ថវិកាចំនួន ១២.១០០ ដុល្លារ |
| ៤-អ្នកស្រី **សៀង សុខណា** | សប្បុរសជននៅរាជធានីភ្នំពេញ | ថវិកាចំនួន ១០.២០០ ដុល្លារ |
| ៥-លោក **ហ៊ីន ហាង** | សប្បុរសជនខ្មែរនៅសហរដ្ឋអាមេរិក | ថវិកាចំនួន ១០.០៩០ ដុល្លារ |
| ៦-លោក **ឆាយ ប៊ឿ** | សប្បុរសជនខ្មែរនៅសហរដ្ឋអាមេរិក | ថវិកាចំនួន ១០.០៧០ ដុល្លារ |
| ៧-លោក **ឌុច អ៊ីន** | សប្បុរសជនខ្មែរនៅសហរដ្ឋអាមេរិក | ថវិកាចំនួន ១០.០៥០ ដុល្លារ |
| ៨-ឧបាសក **ឈឹង ឆើត** | គណៈកម្មការវត្តសុវណ្ណារាម | ថវិកាចំនួន ១០.០៥០ ដុល្លារ |
| ៩-ឧបាសក **ម៉ាំង ផល** | គណៈកម្មការវត្តសុវណ្ណារាម | ថវិកាចំនួន ១០.០០០ ដុល្លារ |
| ១០-អ្នកស្រី **ម៉ឺន សុខឃឿម** | សប្បុរសជននៅខេត្តបាត់ដំបង | ថវិកាចំនួន ១០.០០០ ដុល្លារ |

**ខ_មេដាយប្រាក់ស្ថាបនាជាតិ :**

| | | | |
|---|---|---|---|
| ១-ឧបាសិកា **សុខ ឆែ** | សប្បុរសជនខ្មែរនៅសហរដ្ឋអាមេរិក | ថវិកាចំនួន ៦.០០០ ដុល្លារ |
| ២-លោក **អន យ៉ុត** | សប្បុរសជនខ្មែរនៅប្រទេសបារាំង | ថវិកាចំនួន ៥.៨០០ ដុល្លារ |
| ៣-ឧបាសក **ស៊ុត ឃន** | សប្បុរសជនខ្មែរនៅសហរដ្ឋអាមេរិក | ថវិកាចំនួន ៥.៦០០ ដុល្លារ |
| ៤-ឧបាសក **សុខ ហាច** | សប្បុរសជនខ្មែរនៅសហរដ្ឋអាមេរិក | ថវិកាចំនួន ៥.២០០ ដុល្លារ |
| ៥-លោក **ម៉ាន់ លេខ** | សប្បុរសជនខ្មែរនៅខេត្តបាត់ដំបង | ថវិកាចំនួន ៥.០៥០ ដុល្លារ |

**មាត្រា២:** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និងអភិបាលខេត្តបាត់ដំបង ត្រូវអនុវត្តអនុក្រឹត្យនេះអោយទទួលបានលទ្ធផលល្អ ។/.

រាជធានីភ្នំពេញ ថ្ងៃទី [illegible] ខែ [illegible] ឆ្នាំ២០០៩

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**កន្លែងទទួល:**

-ក្រសួងព្រះបរមរាជវាំង
-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
-អគ្គលេខាធិការដ្ឋានរដ្ឋសភា
-អគ្គលេខាធិការរាជរដ្ឋាភិបាល
-ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
-ដូចមាត្រា ១ និង មាត្រា ២
-រាជកិច្ច
-ឯកសារ-កាលប្បវត្តិ

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

**លេខៈ** ១១៥០ អនក្រ.បក

# អនុក្រឹត្យ
## ស្តីពី
## ការប្រគល់ភារកិច្ចជូនមន្ត្រីរាជការ

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា.
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៨ ចុះថ្ងៃទី២៤ ខែ មករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- បានឃើញអនុក្រឹត្យ លេខ ១៤៨ អនក្រ.បក ចុះថ្ងៃទី ១៩ ខែ ធ្នូ ឆ្នាំ ២០០៦ ស្តីពីការបង្កើតអគ្គនាយកដ្ឋានពន្ធនាគារនៃក្រសួងមហាផ្ទៃ
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

## សម្រេច

**មាត្រា ១ :** ត្រូវបានប្រគល់ភារកិច្ចជូនលោកឧត្តមសេនីយ៍ទោ **លន់ ណេត** ក្របខ័ណ្ឌមន្ត្រីនគរបាលជាតិ ឱ្យបំពេញមុខងារជាអគ្គនាយករង នៃអគ្គនាយកដ្ឋានពន្ធនាគារក្រសួងមហាផ្ទៃ ។

**មាត្រា ២ :** លោកឧត្តមសេនីយ៍ទោ **លន់ ណេត** ត្រូវបានទទួលប្រាក់បំណាច់មុខងារក្នុងមុខតំណែងថ្មីនេះ ស្របតាមព្រះរាជក្រឹត្យលេខ នស/រកត/១២០១/៤៥០ ចុះថ្ងៃទី ០១ ខែ ធ្នូ ឆ្នាំ ២០០១ ស្តីពីបៀវត្សមូលដ្ឋាន និងប្រាក់បន្ទាប់បន្សំ នៃបៀវត្សរបស់មន្ត្រីរាជការស៊ីវិល ។ ក្នុងរយៈពេលបំពេញភារកិច្ចថ្មីនេះ សាមីខ្លួនត្រូវដាក់ពាក្យសុំស្ថិតនៅក្រៅក្របខ័ណ្ឌដើម ។

**មាត្រា ៣ :** បទប្បញ្ញត្តិទាំងឡាយណា ដែលមានខ្លឹមសារផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍ ។

**មាត្រា ៤ :** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ រដ្ឋលេខាធិការ នៃរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ រដ្ឋមន្ត្រី រដ្ឋលេខាធិការគ្រប់ក្រសួងស្ថាប័ន និងសាមីខ្លួន ដូចមានចែងក្នុងមាត្រា១ ត្រូវអនុវត្តអនុក្រឹត្យនេះ ឱ្យមានប្រសិទ្ធភាព ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី ៣០ ខែ មិថុនា ឆ្នាំ ២០០៩

នាយករដ្ឋមន្ត្រី

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**កន្លែងទទួល :**
- *ក្រសួងព្រះបរមរាជវាំង*
- *អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា*
- *អគ្គលេខាធិការដ្ឋានរដ្ឋសភា*
- *អគ្គលេខាធិការរាជរដ្ឋាភិបាល*
- *ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី*
- *ដូចមាត្រា ៤*
- *រាជកិច្ច* ✓
- *ឯកសារ-កាលប្បវត្តិ*

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

រាជរដ្ឋាភិបាលកម្ពុជា
លេខ : ១១៥១ អនក្រ.តត

# អនុក្រឹត្យ
## ស្តីពី
## ការតម្លើងឋានន្តរស័ក្តិនាយនគរបាលជាតិ

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៨ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត /០៥០១/១៧៨ ចុះថ្ងៃទី ២២ ខែ ឧសភា ឆ្នាំ ២០០១ ស្តីពីលក្ខន្តិកៈដោយឡែក នៃក្របខ័ណ្ឌមន្ត្រីនគរបាលជាតិកម្ពុជា
- បានឃើញអនុក្រឹត្យលេខ ១៦ អនក្រ ចុះថ្ងៃទី ២០ ខែ ធ្នូ ឆ្នាំ ១៩៩៣ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃក្រសួងមហាផ្ទៃ
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

## ស ម្រេ ច

**មាត្រា ១ :** ត្រូវបានតម្លើងឋានន្តរស័ក្តិថ្នាក់ **វរសេនីយ៍ឯក** ជូននាយនគរបាលជាតិជាន់ខ្ពស់ នៃក្រសួងមហាផ្ទៃ ចំនួន ០៩ នាក់ ដូចមានរាយនាមខាងក្រោម :

១- លោកវរសេនីយ៍ទោ **ហៀក ឆុន្នី** អត្តលេខ ០២១៣៨
២- លោកវរសេនីយ៍ទោ **ជា សំបូរណ៍** អត្តលេខ ០៦៧៤៩
៣- លោកវរសេនីយ៍ទោ **ឈុក ឈន** អត្តលេខ ០៣៦២៥
៤- លោកវរសេនីយ៍ទោ **ម៉ៅ សាធុច** អត្តលេខ ១២១៧៤
៥- លោកវរសេនីយ៍ទោ **អាំ ផន** អត្តលេខ ១២៧៧០

៦- លោកវរសេនីយ៍ទោ **អោម សារ៉ែន** អត្តលេខ ០២២៧៨

៧- លោកវរសេនីយ៍ទោ **ប៊ូ មុត** អត្តលេខ ០៣៦២៣

៨- លោកវរសេនីយ៍ទោ **និន ប្រុសើរ** អត្តលេខ ០៣៦២៤

៩- លោកវរសេនីយ៍ទោ **ហេង កេងសួគ៌** អត្តលេខ ០៨៩៣ ។

**មាត្រា ២ :** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋមន្ត្រី រដ្ឋលេខាធិការគ្រប់ក្រសួង-ស្ថាប័នដែលពាក់ព័ន្ធ និងសាមីខ្លួនដូចមានចែងក្នុងមាត្រា១ត្រូវអនុវត្តតាមអនុក្រឹត្យនេះចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី ៣០ ខែ មិថុនា ឆ្នាំ ២០០៩

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**កន្លែងទទួល :**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា ២
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

# ព្រះរាជាណាចក្រកម្ពុជា

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

**លេខ...៥២...សសរ**

## សេចក្តីសម្រេច

**ស្តីពី**

**ការបង្កើតអនុគណៈកម្មាធិការអភិវឌ្ឍន៍អភិបាលកិច្ចសាជីវកម្ម**
**ដែលស្ថិតនៅក្រោមគណៈកម្មាធិការដឹកនាំការងារ ដើម្បីអភិវឌ្ឍន៍ផ្នែកឯកជន**

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ ០៣/នស/៩៤ ចុះថ្ងៃទី ០៥ ខែ សីហា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីវិនិយោគនៃព្រះរាជាណាចក្រកម្ពុជា និងព្រះរាជក្រមលេខ នស/រកម/០៣០៣/០០៩ ចុះថ្ងៃទី ២៤ ខែ មិនា ឆ្នាំ ២០០៣ ដែលប្រកាសអោយប្រើច្បាប់ស្តីពីវិសោធនកម្មនៃច្បាប់ស្តីពីវិនិយោគនៃព្រះរាជាណាចក្រកម្ពុជា
- យោងអនុក្រឹត្យលេខ ១៤៩ អនក្រ.បក ចុះថ្ងៃទី ០៣ ខែ តុលា ឆ្នាំ ២០០៨ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា
- សេចក្តីសំរេចរបស់រាជរដ្ឋាភិបាលលេខ ៤៤ សសរ ចុះថ្ងៃទី ២៦ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការបង្កើតគណៈកម្មការដឹកនាំការងារ ដើម្បីអភិវឌ្ឍន៍ផ្នែកឯកជន និងសេចក្តីសំរេចកែសំរួលលេខ ៣២ សសរ ចុះថ្ងៃទី ២៦ ខែ សីហា ឆ្នាំ ២០០៥
- សេចក្តីសំរេចរបស់រាជរដ្ឋាភិបាលលេខ ៤៦ សសរ ចុះថ្ងៃទី ១១ ខែ សីហា ឆ្នាំ ២០០៤ ស្តីពីការបង្កើតអនុគណៈកម្មការដឹកនាំការងារ ដើម្បីអភិវឌ្ឍន៍ផ្នែកឯកជន និងសេចក្តីសំរេចកែសំរួលលេខ ៣២ សសរ ចុះថ្ងៃទី ២៦ ខែ សីហា ឆ្នាំ ២០០៥

- សេចក្តីសម្រេចរបស់រាជរដ្ឋាភិបាលលេខ ៤៧ សសរ ចុះថ្ងៃទី ១១ ខែ សីហា ឆ្នាំ ២០០៤ ស្តីពីការបង្កើតក្រុមការងារតាមវិស័យសំរាប់ធ្វើជាដៃគូរពិភាក្សាការងារជាមួយផ្នែកឯកជន និងសេចក្តីសំរេចកែសំរួលលេខ ៣៧ សសរ ចុះថ្ងៃទី ២១ ខែ សីហា ឆ្នាំ ២០០៦
- សេចក្តីសំរេចរបស់រាជរដ្ឋាភិបាលលេខ ១២ សសរ ចុះថ្ងៃទី ០៧ ខែ មីនា ឆ្នាំ ២០០៧ ស្តីពីការបង្កើតក្រុមការងារតាមវិស័យសំរាប់ធ្វើជាដៃគូពិភាក្សាការងារជាមួយផ្នែកឯកជន
- សេចក្តីសំរេចរបស់រាជរដ្ឋាភិបាលលេខ ៤៥ សសរ ចុះថ្ងៃទី ២៨ សីហា ឆ្នាំ ២០០៧ ស្តីពីការកែសំរួលសេចក្តីសំរេចស្តីពីការបង្កើតគណៈកម្មាធិការ អនុគណៈកម្មាធិការដឹកនាំការងារ ដើម្បីអភិវឌ្ឍន៍ផ្នែកឯកជន និងក្រុមការងារតាមវិស័យ សំរាប់ធ្វើជាដៃគូពិភាក្សាជាមួយផ្នែកឯកជន
- សេចក្តីសំរេចរបស់រាជរដ្ឋាភិបាលលេខ ២៧ សសរ ចុះថ្ងៃទី ១៤ ខែ វិច្ឆិកា ឆ្នាំ ២០០៨ ស្តីពីការកែសំរួលសេចក្តីសំរេចស្តីពីការបង្កើតគណៈកម្មាធិការ អនុគណៈកម្មាធិការដឹកនាំការងារ ដើម្បីអភិវឌ្ឍន៍ផ្នែកឯកជន និងក្រុមការងារតាមវិស័យ សំរាប់ធ្វើជាដៃគូពិភាក្សាជាមួយផ្នែកឯកជន
- អនុលោមតាមតំរូវការចាំបាច់នៃការងារ

# សំរេច

**ប្រការ ១:** ត្រូវបានបង្កើត «អនុគណៈកម្មាធិការអភិវឌ្ឍន៍អភិបាលកិច្ចសាជីវកម្ម» ដែលស្ថិតនៅក្រោមគណៈ-កម្មាធិការដឹកនាំការងារ ដើម្បីអភិវឌ្ឍន៍ផ្នែកឯកជន ដែលមានសមាសភាពដូចខាងក្រោម :

| | | | |
|---|---|---|---|
| ១. | ឯកឧត្តមបណ្ឌិត **អូន ព័ន្ធមុនីរ័ត្ន** | រដ្ឋមន្ត្រីប្រតិភូអមនាយករដ្ឋមន្ត្រី អនុប្រធានគណៈកម្មាធិការដឹកនាំការងារដើម្បីអភិវឌ្ឍន៍ផ្នែកឯកជន និងជារដ្ឋលេខាធិការ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ | ប្រធាន |
| ២. | លោកជំទាវ **ទៀវ ម៉ាលី** | អគ្គទេសាភិបាលរង ធនាគារជាតិនៃកម្ពុជា | អនុប្រធាន |
| ៣. | ឯកឧត្តម **ម៉ិញ ឆានកុសល** | អគ្គនាយក គណៈកម្មការមូលបត្រកម្ពុជា | អនុប្រធាន |
| ៤. | ឯកឧត្តម **កើត រិទ្ធ** | អនុរដ្ឋលេខាធិការ ក្រសួងយុត្តិធម៌ | សមាជិក |
| ៥. | ឯកឧត្តម **ឯម សុគន្ធា** | អនុរដ្ឋលេខាធិការ ក្រសួងពាណិជ្ជកម្ម | សមាជិក |
| ៦. | ឯកឧត្តម **ទី តាយី** | អនុរដ្ឋលេខាធិការ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងជាប្រធានក្រុមប្រឹក្សាជាតិគណនេយ្យ | សមាជិក |
| ៧. | ឯកឧត្តម **ស៊ូ សុជាតិ** | អគ្គនាយករង គណៈកម្មការមូលបត្រកម្ពុជា | សមាជិក |
| ៨. | ឯកឧត្តម **ខា ធុន្នី** | អគ្គលេខាធិការរង គណៈកម្មាធិការតំបន់សេដ្ឋកិច្ចពិសេសកម្ពុជា នៃក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា | សមាជិក |
| ៩. | ឯកឧត្តម **ហ៊ែល ចំរើន** | ប្រធានផ្នែកសិក្សា និងវិភាគគោលនយោបាយអភិបាលកិច្ច ឧត្តមក្រុមប្រឹក្សាសេដ្ឋកិច្ចជាតិ | សមាជិក |

១០. លោក ម៉ី ទាវ៉ាន់ ប្រធាននាយកដ្ឋានឧស្សាហកម្មហិរញ្ញវត្ថុ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ សមាជិក

១១. សហប្រធានផ្នែកឯកជននៃក្រុមការងារផ្នែកនីតិកម្ម ពន្ធដារ និងអភិបាលកិច្ច សមាជិក

១២. សហប្រធានផ្នែកឯកជននៃក្រុមការងារផ្នែកសេវាកម្មធនាគារ និងហិរញ្ញវត្ថុ សមាជិក

១៣. អគ្គនាយកនៃក្រុមហ៊ុនផ្សារមូលបត្រកម្ពុជា សមាជិក

១៤. ប្រធានសភាពាណិជ្ជកម្មកម្ពុជា សមាជិក

១៥. ប្រធានសភាមុខរបរ និងមីក្រូសហគ្រាសកម្ពុជា សមាជិក

១៦. ប្រធានក្លិបធុរកិច្ចអន្តរជាតិនៃកម្ពុជា សមាជិក

១៧. ប្រធានសមាគមឧស្សាហកម្ម តូច មធ្យម ភ្នំពេញ សមាជិក

១៨. ប្រធានសមាគមធនាគារនៃកម្ពុជា សមាជិក

១៩. ប្រធានសមាគមក្រុមហ៊ុនមូលបត្រកម្ពុជា សមាជិក

២០. ប្រធានសមាគមធានារ៉ាប់រងទូទៅកម្ពុជា សមាជិក

២១. ប្រធានគណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជា សមាជិក

២២. ប្រធានសមាគមអភិវឌ្ឍអចលនវត្ថុកម្ពុជា សមាជិក

២៣. ប្រធានសមាគមអ្នកវាយតំលៃអចលនវត្ថុជាតិកម្ពុជា សមាជិក

២៤. ប្រធានវិទ្យាស្ថានគណនេយ្យករជំនាញ និងសវនករកម្ពុជា សមាជិក

២៥. លោក ឈុន សម្បត្តិ ប្រធាននាយកដ្ឋានគ្រប់គ្រងការបោះផ្សាយលក់មូលបត្រ គណៈកម្មការមូលបត្រកម្ពុជា លេខាធិការ

**ប្រការ ២:** អនុគណៈកម្មាធិការនេះ មានតួនាទី និង ភារកិច្ច ដូចខាងក្រោម:

- រៀបចំគោលនយោបាយ និង យុទ្ធសាស្រ្តស្តីពីការអភិវឌ្ឍន៍អភិបាលកិច្ចសាជីវកម្មសម្រាប់វិស័យមូលបត្រ និង វិស័យធុរកិច្ចពាក់ព័ន្ធដទៃទៀត
- រៀបចំលិខិតបទដ្ឋានគតិយុត្ត និង សេចក្តីណែនាំផ្សេងៗពាក់ព័ន្ធនឹងអភិបាលកិច្ចសាជីវកម្ម
- ជំរុញ តាមដាន និង វាយតម្លៃការអនុវត្តអភិបាលកិច្ចសាជីវកម្មរបស់ផ្នែកឯកជន
- ស្វែងរកហិរញ្ញប្បទានផ្សេងៗពីដៃគូអភិវឌ្ឍន៍នានា ដើម្បីអភិវឌ្ឍអភិបាលកិច្ចសាជីវកម្មនៅកម្ពុជា
- រាយការណ៍ជាប្រចាំជូនប្រមុខនៃរាជរដ្ឋាភិបាលពីការអភិវឌ្ឍនៃអភិបាលកិច្ចសាជីវកម្ម តាមរយៈគណៈកម្មាធិការដឹកនាំការងារដើម្បីអភិវឌ្ឍន៍ផ្នែកឯកជន ។

**ប្រការ ៣:** ដើម្បីបំពេញការងារអោយបានពេញលេញ អនុគណៈកម្មាធិការនេះ អាចបង្កើតក្រុមការងារទៅតាមវិស័យតាមការចាំបាច់ ។

**ប្រការ ៤:** ឯកឧត្តម លោកជំទាវ អស់លោក លោកស្រី ដែលមានឈ្មោះក្នុងអនុគណៈកម្មាធិការនេះ ត្រូវចូលរួមប្រជុំតាមការអញ្ជើញរបស់ប្រធាន ឬ អនុប្រធាន (តាមការចាត់តាំងរបស់ប្រធាន) ក្នុងករណីប្រធានអវត្តមាន ។ អនុគណៈកម្មាធិការ ប្រើប្រាស់ត្រារបស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ដើម្បីបំពេញតួនាទី និង ភារកិច្ចរបស់ខ្លួន ។

ការសំរេចរបស់ឯកឧត្តម លោកជំទាវ អស់លោក លោកស្រី ដែលត្រូវបានទទួលការចាត់តាំងអោយចូលរួមប្រជុំជំនួស ត្រូវបានចាត់ទុកថា ជាការសំរេចផ្លូវការក្នុងនាមឯកឧត្តម លោកជំទាវ អស់លោក លោកស្រី ជាសមាជិកនៃអនុគណៈកម្មាធិការដែលអវត្តមាន ។

**ប្រការ ៥:** ក្នុងករណីចាំបាច់ និង ដោយមានការយល់ព្រមជាមុនពីប្រធានអនុគណៈកម្មាធិការ សហប្រធានផ្នែកឯកជននៃក្រុមការងារផ្នែកនីតិកម្ម ពន្ធដារ និងអភិបាលកិច្ច និង សហប្រធានផ្នែកឯកជននៃក្រុមការងារផ្នែកសេវាកម្មធនាគារ និងហិរញ្ញវត្ថុ ព្រមទាំងប្រធានអង្គការ- សមាគមផ្នែកឯកជនអាចអញ្ជើញសមាជិករបស់ខ្លួនមកពីផ្នែកឯកជនដែលមានជំនាញពាក់ព័ន្ធ អោយចូលរួមក្នុងកិច្ចប្រជុំអនុគណៈកម្មាធិការ។ ប្រធានអនុគណៈកម្មាធិការមានសិទ្ធអញ្ជើញសហប្រធាន ផ្នែកឯកជននៃក្រុមការងារតាមវិស័យពាក់ព័ន្ធដទៃទៀតដើម្បីចូលរួមប្រជុំតាមការចាំបាច់ ។

**ប្រការ ៦:** រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងជាប្រធានគណៈកម្មាធិការដឹកនាំការងារ ដើម្បីអភិវឌ្ឍន៍ផ្នែកឯកជន និងអនុគណៈកម្មាធិការទាំងអស់ រដ្ឋមន្ត្រីគ្រប់ក្រសួង គ្រប់អភិបាលរាជធានី/ខេត្ត គ្រប់ប្រធានស្ថាប័ន/អង្គភាពដែលពាក់ព័ន្ធ ព្រមទាំងសមាសភាពដូចមានចែងក្នុងប្រការ ១ ត្រូវទទួលអនុវត្តសេចក្តីសំរេចនេះ អោយមានប្រសិទ្ធភាពខ្ពស់ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី ២៧ ខែ កក្កដា ឆ្នាំ ២០០៩

សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន

**<u>ចំលងជូន:</u>**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុនសែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ប្រធាន «ក.អ.ក»
- ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី
- ដូចប្រការ ១ និង ៦ ដើម្បីអនុវត្ត
- ឯកសារ- កាលប្បវត្តិ

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

លេខ: ៦១១.....សហវ.ប្រក.គរ.

រាជធានីភ្នំពេញ , ថ្ងៃទី ២៤ ខែ កក្កដា ឆ្នាំ ២០០៩

# ប្រកាស
# ស្ដីពី
# ការប្រើប្រាស់ព័ត៌មានដែលទទួលបានដោយមន្ត្រីគយ

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ចុះថ្ងៃទី២៥ខែកញ្ញា ឆ្នាំ ២០០៨ ស្ដីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២ / នស / ៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្ដីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ស្ដីពីការបង្កើតក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៧០៧/០១៧ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ ២០០៧ ដែលប្រកាសឲ្យប្រើច្បាប់ស្ដីពីគយ
- បានឃើញអនុក្រឹត្យលេខ ០៤ អនក្រ.បក ចុះថ្ងៃទី ២០ ខែ មករា ឆ្នាំ ២០០០ ស្ដីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ១៣៤ អនក្រ.បក ចុះថ្ងៃទី ១៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្ដីពីការតម្លើងទីចាត់ការគយ និងរដ្ឋាករ នាយកដ្ឋានពន្ធដារ និងរតនាគារជាតិ នៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុឱ្យទៅជាអគ្គនាយកដ្ឋានគយ និងរដ្ឋាករកម្ពុជា អគ្គនាយកដ្ឋានពន្ធដារ និងអគ្គនាយកដ្ឋានរតនាគារជាតិ ស្ថិតក្រោមការគ្រប់គ្រងរបស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ១៥២ អនក្រ.បក ចុះថ្ងៃទី ០៦ ខែ តុលា ឆ្នាំ ២០០៨ ស្ដីពីការបង្កើតនាយកដ្ឋានរដ្ឋាករ នាយកដ្ឋានរបបគយ និងនាយកដ្ឋានគ្រប់គ្រងតំបន់រួចពន្ធ ស្ថិតក្រោមការគ្រប់គ្រងរបស់អគ្គនាយកដ្ឋានគយ និងរដ្ឋាករកម្ពុជា នៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- យោងតាមសំណូមពរការងារចាំបាច់របស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

## សម្រេច

**ប្រការ ១.-**

ព័ត៌មានដែលទទួលបានដោយមន្ត្រីគយនៅក្នុងការគ្រប់គ្រង ឬការអនុវត្តច្បាប់ អាចប្រើប្រាស់បានសម្រាប់តែគោលបំណងដែលមានចែងក្នុងច្បាប់ជាធរមាន [illegible]ការ អនុញ្ញាតដោយឡែកក្រោមបញ្ញត្តិនានានៃប្រកាសនេះ ។

ព័ត៌មានដែលទទួលបានដោយមន្ត្រីគយនៅក្នុងការគ្រប់គ្រង ឬការអនុវត្តច្បាប់រួមមាន ៖

- ព័ត៌មានដែលត្រូវបានផ្តល់ជូនរដ្ឋបាលគយ ដោយនីតិបុគ្គល ឬរូបវន្តបុគ្គលពាក់ព័ន្ធនឹងការនាំចេញ ការនាំចូល ការដឹកជញ្ជូន ឬការធ្វើសន្និធិទំនិញ និងពីតំណាងស្របច្បាប់របស់បុគ្គលទាំងនេះ រាប់បញ្ចូលទាំងដើងសារគយ ឬភ្នាក់ងារតំណាងស្របច្បាប់នានា

- ព័ត៌មានដែលត្រូវបានផ្តល់ដោយមន្ត្រីនៃស្ថាប័ន និងអាជ្ញាធរផ្សេងទៀតរបស់រាជរដ្ឋាភិបាល

- ព័ត៌មានដែលត្រូវបានផ្តល់ដោយរដ្ឋបាលគយនិងភ្នាក់ងារអនុវត្តច្បាប់បរទេសផ្សេងទៀត

- ព័ត៌មានសំងាត់ ឬមានវេទយិតភាពពាក់ព័ន្ធនឹងបញ្ហាផ្ទៃក្នុងអង្គភាព ជាពិសេសព័ត៌មានពាក់ព័ន្ធនឹងប្រតិបត្តិការរបស់រដ្ឋបាលគយ ព័ត៌មានសន្តិសុខ ឬព័ត៌មានពាក់ព័ន្ធនឹងការស៊ើបអង្កេត និងការអនុវត្តច្បាប់ ។

**ប្រការ ២.-**

មន្ត្រីគយមិនត្រូវប្រើប្រាស់ព័ត៌មានសំងាត់ ឬមានវេទយិតភាព ឬមានលក្ខណៈពាណិជ្ជកម្មសម្រាប់ប្រយោជន៍បុគ្គលផ្ទាល់ខ្លួន ឬសម្រាប់តម្រូវការដែលគ្មានការអនុញ្ញាតណាមួយឡើយ ។

មន្ត្រីគយមិនត្រូវយកចេញពីការិយាល័យគយនូវឯកសារ ឬព័ត៌មានផ្លូវការណាមួយ លើកលែងតែមានតម្រូវការសម្រាប់អនុវត្តភារកិច្ចរបស់ខ្លួន និងមិនត្រូវផ្តល់ព័ត៌មាន ឬឯកសារពាក់ព័ន្ធនឹងប្រតិបត្តិការរបស់រដ្ឋបាលគយទៅបុគ្គលដែលគ្មានការអនុញ្ញាត ។ មន្ត្រីគយដែលប្រព្រឹត្តល្មើសនឹងបញ្ញត្តិនៃប្រកាសនេះនឹងត្រូវទទួលការផ្តន្ទាទោសតាមច្បាប់ស្តីពីគយ ឬបទប្បញ្ញត្តិផ្សេងទៀតជាធរមាន ។

**ប្រការ ៣.-**

មន្ត្រីគយត្រូវបានអនុញ្ញាតឱ្យធ្វើទំនាក់ទំនង ឱ្យផ្តល់កិច្ចសហការ ឬអនុញ្ញាតឱ្យមានការត្រួតពិនិត្យព័ត៌មានរាប់បញ្ចូលទាំង សៀវភៅ បញ្ជី កំណត់ត្រា ឯកសារ ឬព័ត៌មានផ្សេងទៀតដែលទទួលបាននៅក្នុងការបំពេញភារកិច្ចរបស់ខ្លួនជូនទៅបុគ្គល ឬអង្គការនានាដូចខាងក្រោម ៖

- មន្ត្រីមានសមត្ថកិច្ចនៃអគ្គនាយកដ្ឋានគយ និងរដ្ឋាករកម្ពុជា

- បុគ្គលដែលមានសិទ្ធិស្របច្បាប់ទទួលព័ត៌មាន រាប់បញ្ចូលទាំងមន្ត្រីនគរបាលយុត្តិធម៌ និងមន្ត្រីតុលាការ

- អាជ្ញាធរមូលដ្ឋាន និងអាជ្ញាធរថ្នាក់ជាតិរាប់បញ្ចូលទាំងនគរបាល កងរាជអាវុធហត្ថ និងភ្នាក់ងារផ្សេងទៀតដែលបានចូលរួមក្នុងប្រតិបត្តិការអនុវត្តច្បាប់ជាមួយរដ្ឋបាលគយ

- មន្ត្រីមានសមត្ថកិច្ចនៃអគ្គនាយកដ្ឋានពន្ធដារ តាមការកំណត់របស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

- បុគ្គលណាមួយដែលត្រូវបានទទួលការអនុញ្ញាតឱ្យធ្វើជាភ្នាក់ងារ ឬតំណាងបុគ្គលដែលបានផ្តល់ព័ត៌មាន សៀវភៅ បញ្ជី កំណត់ត្រា និងឯកសារនានា រាប់បញ្ចូលទាំងភ្នាក់ងារគយ តំណាងស្របច្បាប់ និងនិយោជិកជាដើម

- តំណាងរដ្ឋបាលគយ និងភ្នាក់ងារអនុវត្តច្បាប់បរទេសផ្សេងទៀត ដែលអគ្គនាយកដ្ឋានគយ និងរដ្ឋាករកម្ពុជាមានកិច្ចព្រមព្រៀងផ្លូវការស្តីពីកិច្ចសហប្រតិបត្តិការ និងការជួយគ្នាទៅវិញទៅមក

- បុគ្គល និងអង្គការផ្សេងទៀតដែលមានការឯកភាពពីអគ្គនាយកគយ និងរដ្ឋាករកម្ពុជា។

**ប្រការ ៤ .-**

តាមការសម្រេចរបស់តុលាការមានសមត្ថកិច្ច មន្ត្រីគយអាចផ្តល់ជាបន្ទាល់ពាក់ព័ន្ធនឹងព័ត៌មានដែលទទួលបាន ក្រោមបញ្ញត្តិនៃច្បាប់ស្តីពីគយ និងរៀបចំទូវសៀវភៅ បញ្ជី កំណត់ត្រា និងឯកសារនានាជូនតុលាការ ។

**ប្រការ ៥ .-**

មន្ត្រីគយដែលបានបញ្ចេញព័ត៌មានតាមបញ្ញត្តិនៃប្រកាសនេះ ត្រូវធ្វើរបាយការណ៍ជាលាយលក្ខណ៍អក្សរជូនអគ្គនាយកគយ និងរដ្ឋាករកម្ពុជា ដោយមានរៀបរាប់ពីព័ត៌មានដែលបានផ្តល់ បុគ្គលដែលត្រូវបានផ្តល់ និងព័ត៌មានពាក់ព័ន្ធផ្សេងៗទៀត ។

**ប្រការ ៦.-**

បទប្បញ្ញត្តិទាំងឡាយណា ដែលមានខ្លឹមសារផ្ទុយពីប្រកាសនេះត្រូវចាត់ទុកជានិរាករណ៍។

**ប្រការ ៧.-**

ប្រតិភូរាជរដ្ឋាភិបាលទទួលបន្ទុកជាអគ្គនាយកគយ និងរដ្ឋាករកម្ពុជា អគ្គលេខាធិការ អគ្គនាយក នាយកខុទ្ទកាល័យ ប្រធាននាយកដ្ឋាន និងអង្គភាពនានាក្រោមឱវាទក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ព្រមទាំងបុគ្គល និងស្ថាប័នពាក់ព័ន្ធផ្សេងទៀតត្រូវអនុវត្តតាមខ្លឹមសារប្រកាសនេះ ឲ្យមានប្រសិទ្ធិភាពចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

ឧបនាយករដ្ឋមន្ត្រី
រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

គាត ឈន់

**ចម្លងជូន៖**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ទីស្តីការគណៈរដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា
  "ដើម្បីជូនជ្រាប"
- ដូចប្រការ ៧
- សភាពាណិជ្ជកម្មកម្ពុជា
  "ដើម្បីសហការផ្សព្វផ្សាយ និងអនុវត្ត"
- រាជកិច្ច
- ឯកសារ - កាលប្បវត្តិ

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

MINISTRY OF ECONOMY AND FINANCE

**ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ**

លេខ: ៦១៥ សហវ.ប្រកា.អគ.

រាជធានីភ្នំពេញ, ថ្ងៃទី ២៤ ខែកក្កដា ឆ្នាំ ២០០៩

# ប្រកាស

## ស្តីពី

## ការសម្រុះសម្រួលបទល្មើសគយ

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស / រកត / ០៩០៨ / ១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២ / នស / ៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៧០៧/០១៧ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ ២០០៧ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីគយ
- បានឃើញអនុក្រឹត្យលេខ ០៤ អនក្រ.បក ចុះថ្ងៃទី ២០ ខែ មករា ឆ្នាំ ២០០០ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ១៣៤ អនក្រ.បក ចុះថ្ងៃទី ១៩ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតម្លើងទីចាត់ការគយ និងរដ្ឋាករ នាយកដ្ឋានពន្ធដារ និងរតនាគារជាតិ នៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុឱ្យទៅជាអគ្គនាយកដ្ឋានគយ និងរដ្ឋាករកម្ពុជា អគ្គនាយកដ្ឋានពន្ធដារ និងអគ្គនាយកដ្ឋានរតនាគារជាតិ ស្ថិតក្រោមការគ្រប់គ្រងរបស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ១៩២ អនក្រ.បក ចុះថ្ងៃទី ០៦ ខែ តុលា ឆ្នាំ ២០០៨ ស្តីពីការបង្កើតនាយកដ្ឋានរដ្ឋាករ នាយកដ្ឋានរបបគយ និងនាយកដ្ឋានគ្រប់គ្រងទំនិញនាំចូល ស្ថិតក្រោមការគ្រប់គ្រងរបស់អគ្គនាយកដ្ឋានគយ និងរដ្ឋាករកម្ពុជា ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- យោងតាមសំណូមពរការងារចាំបាច់របស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

ផ្លូវលេខ ៩២ សង្កាត់វត្តភ្នំ ខណ្ឌដូនពេញ រាជធានីភ្នំពេញ កម្ពុជា
St,92, Sangkat Wat Phnom, Khan Daun Penh, Phnom Penh, CAMBODIA.
ទូរសព្ទ : ៨៥៥-២៣-៧២៤ ៦៦៤ ទូរសារ : ៨៥៥-២៣-៤២៧ ៧៩៨
Phone : 855-23-724 664 Fax : 855-23-427 798

## សម្រេច

**ប្រការ ១.-**

រដ្ឋបាលគយមានសិទ្ធិសម្រុះសម្រួលចំពោះបទល្មើសគយ តាមបញ្ញត្តិមាត្រា ៧៧ នៃច្បាប់ស្តីពីគយ ។ សិទ្ធិសម្រុះសម្រួលនេះ ប្រើប្រាស់ចំពោះតែការពិន័យជាប្រាក់តែប៉ុណ្ណោះ ។

ការសម្រុះសម្រួលអាចធ្វើទៅបាន តែនៅមុនពេលមានសាលក្រមរបស់តុលាការមានសមត្ថកិច្ចប៉ុណ្ណោះ ។

**ប្រការ ២.-**

រដ្ឋបាលគយមានសិទ្ធិសម្រុះសម្រួលដូចតទៅ ៖

- ប្រធានទីស្នាក់ការគយ និងរដ្ឋាករមានសិទ្ធិសម្រុះសម្រួលបទល្មើសគយគ្រប់ប្រភេទពាក់ព័ន្ធនឹងទំនិញដែលមានតម្លៃមិនលើសពី មួយលានប្រាំសែន (១.៥០០.០០០) រៀល
- ប្រធានការិយាល័យ ឬប្រធានសាខាគយ និងរដ្ឋាករ មានសិទ្ធិសម្រុះសម្រួលបទល្មើសគយគ្រប់ប្រភេទពាក់ព័ន្ធនឹងទំនិញដែលមានតម្លៃមិនលើសពី បួនលាន (៤.០០០.០០០) រៀល
- អគ្គនាយកគយ និងរដ្ឋាករកម្ពុជា មានសិទ្ធិសម្រុះសម្រួលបទល្មើសគយគ្រប់ប្រភេទ ។

**ប្រការ ៣ .-**

